# របាយការណ៍សង្ខេប
# របស់ពុទ្ធិកសមាគមកម្ពុជរដ្ឋនៃប្រទេសកម្ពុជា
# ២០០៧-២០០៩

## I/ ប្រវត្តិ និងការប្រព្រឹត្តទៅរបស់ពុទ្ធិកសមាគមកម្ពុជរដ្ឋ :

ពុទ្ធិកសមាគមកម្ពុជរដ្ឋ ត្រូវបានបង្កើតឡើងតាំងពីឆ្នាំ ១៩៥២ ក្រោមព្រះរាជតម្រិះផ្តួចផ្តើមរបស់សម្តេច**ព្រះមហាសង្ឃរាជ ជួន ណាត** (ជោតញ្ញាណោ) កាលនោះព្រះអង្គនៅជាព្រះសង្ឃនាយកនៅឡើយ។ សមាគមនេះ ស្ថិតនៅក្រោមព្រះរាជឧបត្ថម្ភដ៏ខ្ពង់ខ្ពស់ពីព្រះមហាកក្សត្រជាទីសក្ការៈ និងការឧបត្ថម្ភរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដែលក្នុងទសវត្សឆ្នាំទី ៦០-៧០ មានវរជនជាច្រើនរូប ដែលក្នុងនោះមាន លោក **រ៉ាយ ប៊ុត** លោក **ប៉ុណ្ណ ចន្ទម៉ុល** និងលោកជំទាវ **ណៃ ទ៉ាឡង់តាំង** ជាដើមធ្វើជាប្រធាន។

ដោយនឹកស្តាយស្នាព្រះហស្តនិងស្នាដៃដ៏មានឧបការគុណចំពោះសង្គមជាតិ និងព្រះពុទ្ធសាសនានិងតម្លៃគតិបណ្ឌិតរបស់បុព្វបុរសយើងដែលបានបង្កើត ព.ស.ក នេះឡើង ទើបមានព្រះសង្ឃនិងពុទ្ធសាសនិកមួយក្រុមបានស្ម័គ្រព្រះទ័យ និងស្រុះស្រួលចិត្តរៀបចំបង្កើត ព.ស.ក នេះឡើងវិញ នៅឆ្នាំ ១៩៩៤។ ព.ស.ក បានរៀបចំគណៈកម្មការនាយកដឹកនាំបណ្តោះអាសន្នដោយ ឯកឧត្តម ចាន់ វ៉ែន ហើយមានកិត្តិយសដោយទទួលបានការប្រោសប្រណីពី **ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តមសីហនុ** និង **សម្តេចព្រះអគ្គមហេសី** ជាព្រះប្រធានកិត្តិយសរបស់សមាគមនៅ ថ្ងៃទី៣១ ធ្នូ ឆ្នាំ១៩៩៤។ នៅថ្ងៃទី៣០ ខែមករា ឆ្នាំ១៩៩៥ **សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម** ប្រធានព្រឹទ្ធសភា។ នៅថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៥ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រ កម្ពុជា។ នៅថ្ងៃ ទី២៤ ខែសីហា ឆ្នាំ២០០៩ **សម្តេចអគ្គមហាពញាចក្រី ហេង សំរិន** ប្រធានសភាជាតិនៃព្រះរាជា ណាចក្រកម្ពុជា និង **សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ** កាលនោះជានាយករដ្ឋមន្ត្រីទី១ នៅក្នុងឆ្នាំ ២០០១ និង **សម្តេចមហាសង្ឃរាជទាំង២គណៈ** ក៏ទ្រង់ព្រះមេត្តា និងមេត្តាផ្តល់សេចក្តីអនុគ្រោះទទួលជាសមាជិកកិត្តិយសរបស់ពុទ្ធិក សមាគមកម្ពុជរដ្ឋផងដែរ ហើយទន្ទឹមនេះ ក៏មានការគាំទ្រនិងអនុញ្ញាតពីក្រសួងធម្មការនិងសាសនា។

- **គោលបំណង:**

គោលបំណង នៃអង្គសិក្ខាសាលាគឺស្វែងរកយុទ្ធសាស្ត្រ និងយន្តការការងារថ្មីដើម្បីពង្រីកសមាជិកភាព និងស្រង់យកគំនិតអភិវឌ្ឍន៍ការងាររបស់ពុទ្ធិកសមាគមកម្ពុជរដ្ឋ សម្រាប់ពេលអនាគតនិងដើម្បីចុះបញ្ជីសមាជិកសាជាថ្មី នៃពុទ្ធិកសមាគមពិភពលោកឡើងវិញ។ ស្វែងរកគំនិតរួមគ្នា ក្នុងការរួមចំណែកកសាងវប្បធម៌សន្តិភាព សីលធម៌សង្គម និងបណ្តុះបណ្តាលធនធានមនុស្សប្រកបដោយគុណធម៌ ឈានទៅរកការរួមចំណែកកសាងសង្គមជាតិ និងទ្រទ្រង់លើកដំកើងព្រះពុទ្ធសាសនាដែលជាសាសនារបស់រដ្ឋ។

## II/ ការរៀបចំរចនាសម្ព័ន្ធការងារ

នៅថ្ងៃទី៤ ខែមេសា ឆ្នាំ២០០១ គណៈកម្មាធិការនាយកបណ្តោះអាសន្ន បានសម្រេចរៀបចំមហាសន្និបាតលើកទី១ របស់ពុទ្ធិកសមាគមកម្ពុជរដ្ឋ ដើម្បីជ្រើសតាំងគណៈកម្មាធិការនាយក ពេញសិទ្ធិរបស់ពុទ្ធិក សមាគមកម្ពុជរដ្ឋ សម្រាប់ អាណត្តិ ២ឆ្នាំម្តង។ មហាសន្និបាតពុទ្ធិកសមាគមកម្ពុជរដ្ឋលើកទី១ បានជ្រើសរើសបេក្ខជន បេក្ខនារី ចំនួន១៣រូប អាណត្តិទី២ មាន ១៧រូបអាណត្តិទី៣មាន២១រូបដឹកនាំដោយ **ឯកឧត្តម ចាន់ វ៉េន** ជាប្រធាន។ នៅក្នុងអាណត្តិទី៤ មហាសន្និបាតជ្រើសរើស ឧកញ៉ាមហាឧបាសិកា ញឹក ប៊ុនថា ជាប្រធានដឹកនាំបន្ត មានសមាជិក២៧រូប និងមានឧត្តមប្រឹក្សា ទីប្រឹក្សាជាមន្ត្រីសង្ឃ និងឥស្សរជន បញ្ញវ័នជាច្រើនរូបនិងមានការជួយឧបត្ថម្ភ ពីក្រសួងធម្មការនិងសាសនា ដើម្បីពង្រឹកកម្លាំងចូលរួមឱ្យទូលំទូលាយក្នុងទូទាំងប្រទេសដោយខំធ្វើសកម្មភាពផ្សព្វផ្សាយព្រះធម៌អប់រំវប្បធម៌ និងប្រជាសង្គ្រោះចូលរួមកសាងសង្គមឆ្ពោះទៅភ្ជាប់ខ្លួនជាមួយពុទ្ធិកសមាគមពិភពលោក (The World fellowship of Buddhist) ជាថ្មីដូចសម័យអតីតកាលឡើងវិញ។

ដើម្បីដំណើរការសកម្មភាពការងារឱ្យទទួលបានជោគជ័យគណៈកម្មាធិការនាយក និងលេខាធិការដ្ឋានអចិន្ត្រៃយ៍របស់ពុទ្ធិកសមាគមបានបែងចែកភារកិច្ចការងាររបស់ខ្លួនស្របតាមលក្ខន្តិកៈរួមមាន :

១- គណៈកម្មការឃោសនាអប់រំ បោះពុម្ព និងផ្សព្វផ្សាយ

២- គណៈកម្មការអប់រំសីលធម៌ និងវប្បធម៌សន្តិភាព

៣- គណៈកម្មការមនុស្សធម៌ និងសង្គហធម៌

៤- គណៈកម្មការទំនាក់ទំនងសាធារណៈ

៥- គណៈកម្មការគ្រប់គ្រងហិរញ្ញវត្ថុ

## III/ សកម្មភាពការងារ

### ១- គណៈកម្មការឃោសនាអប់រំ បោះពុម្ព និងផ្សព្វផ្សាយ

ក/ បោះពុម្ពទស្សនាវដ្តី "**ពន្លឺពុទ្ធចក្រ** " ក្នុងមួយឆ្នាំមានពីរលេខ។ បោះពុម្ព ចំនួន០៩លេខ ស្មើ៩០០ច្បាប់ ដោយប្រើថវិកាបោះពុម្ពរបស់សប្បុរសជនជួយឧបត្ថម្ភខ្លះ និងពីថវិកាសមាគមខ្លះ។

ខ/ **សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី ទេព វង្ស** សម្តេចព្រះមហាសង្ឃរាជ នៃព្រះរាជាណាចក្រកម្ពុជា ដោយមាន តំណាងពុទ្ធិកសមាគមកម្ពុជរដ្ឋចូលរួមផង បានយាង និងចុះទៅវត្តកងត្រង់ហ៊ើង ស្រុកកងមាស ខេត្តកំពង់ចាម វត្តទេពធីតា រាម ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង ផ្សព្វផ្សាយទូលាយ ក្នុងជួរព្រះសង្ឃ អាចារ្យ គណៈកម្មការ មន្ត្រីរាជការ អ្នកមុខ អ្នកការ ទាហាន ស៊ីវិល យុវវ័យ ជាច្រើនរយនាក់ មានថ្នាក់ដឹកនាំ ខេត្ត-ស្រុក-ឃុំ-សង្កាត់ និងដោយ មានពិធីប្រទានព្រះរាជអំណោយផង។

គ/ **សម្តេចព្រះមហាសុមេធាធិបតី នន្ទ ង៉ែត** សម្តេចព្រះសង្ឃនាយក នៃព្រះរាជាណាចក្រកម្ពុជា សម្តេចព្រះសង្ឃនាយករង សម្តេចគ្រប់អង្គ ព្រះរាជាគណៈ ក្នុងគណអធិបតីកិត្តិយស និងព្រះសង្ឃ សមណនិស្សិត ជាច្រើនអង្គ បានយាង-និមន្តចុះទៅធ្វើការអប់រំផ្សព្វផ្សាយខ្លឹមសារព្រះពុទ្ធសាសនា នៅតាមទីប្រជុំជន នៅតាមសាលារៀន កន្លែងប្រារព្ធពិធីបុណ្យផ្សេងៗ

ក្នុងជួរពុទ្ធសាសនិក និងសិស្សានុសិស្ស ជាច្រើនលើកច្រើនសារ ដោយសហការល្អជាមួយអាជ្ញាធរមូលដ្ឋាន និងនាយកសាលានីមួយៗ។

ឃ/ បោះពុម្ពសៀវភៅធម៌ខ្លីៗ ជាបន្តបន្ទាប់ចែកជាធម្មទានតាមរយៈប្រារព្ធពិធីបុណ្យផ្សេងៗមានពិធីមាឃបូជា ពិសាខបូជាជាដើម។ បានធ្វើសិក្ខាសាលាក្រោមប្រធានបទរួមគ្នាបង្កើនលើកកំពស់តួនាទីពុទ្ធិកសមាគមកម្ពុជរដ្ឋ ដើម្បីរក្សាអត្ថិភាពអភិវឌ្ឍព្រះពុទ្ធសាសនា។

ង/ វេរប្រគេន ព្រះត្រៃបិដក វចនានុក្រមខ្មែរ បទានុក្រមរតនវត្ត និងទូសម្រាប់ដំកល់ព្រះត្រៃបិដក គិតដល់ខែវិច្ឆិកា ឆ្នាំ២០០៩នេះមាន ១០០ចប់ គឺ ១០០វត្ត គិតជាទឹកប្រាក់ ៥៦.៩៥២ដុល្លា។ ដោយឡែកបើគិតក្នុងឆ្នាំ២០០៨ និង ២០០៩នេះមានចំនួន៥៦ចប់ ស្មើនឹងទឹកប្រាក់ ៣២.៤០០ដុល្លា ជាថវិកានៃសទ្ធាចូលរួមរបស់ពុទ្ធបរិស័ទនៅនាទីឈ្វេង យល់ព្រះពុទ្ធសានា និងមហាឧបាសិកាញឹក ប៊ុនថា។

## ២-ការអប់រំសីលធម៌ និងវប្បធម៌សន្តិភាព

ក/ ធ្វើយុទ្ធនាការផ្សព្វផ្សាយតាមប្រព័ន្ធព័ត៌មាន មានវិទ្យុនិងទូរទស្សន៍ រួមចំណែកបំបាត់រាល់ទង្វើអសកម្មនានា រួមមានការទប់ស្កាត់អំពើហិង្សា ការទប់ស្កាត់ការរីករាលដាលនៃជម្ងឺអេដស៍ រួមចំណែកការស្តារសីលធម៌និងប្រពៃណីរបៀបរស់នៅដ៏ថ្លៃថ្នូររបស់ សង្គមខ្មែរកាត់បន្ថយក្មេងទំនើងនិងការជួយសង្គ្រោះគ្នាដើម្បីឱ្យមានភាពសុខសាន្តក្នុងសង្គមជាតិ។

ខ/ ផ្សព្វផ្សាយតាមគេហទំព័រ www.bacambodia.org ចាប់ពីខែឧសភា ឆ្នាំ ២០០៩។ រាល់សកម្មភាពរបស់ ព.ស.ក ដែលមានការគាំទ្រពីរាជរដ្ឋាភិបាល ពីសម្តេចអគ្គមហាសង្ឃរាជ សម្តេចព្រះសង្ឃនាយក ព្រះសង្ឃនាយករង មហាជនទាំងក្នុងប្រទេស និងក្រៅប្រទេសពិសេសគឺការផ្សព្វផ្សាយព្រះធម៌ដែលមានសន្ទនានៅក្នុងព្រះត្រៃបិដកនៅអាគារធិកាពុទ្ធិកសិក្សារៀងរាល់ថ្ងៃអាទិត្យ និងនាទីឈ្វេងយល់ព្រះពុទ្ធសាសនានិងសង្គមប្រព្រឹត្តិទៅនៅប៉ុស្ត CTN រៀងរាល់ខែ បានជោគជ័យល្អប្រសើរ។ ក្នុងឆ្នាំ ២០០៧ អស់ថវិកាចំនួន **$១២៨០០ដុល្លា** ឆ្នាំ ២០០៨ អស់ថវិកា **$១៦៩០០ដុល្លា** ឆ្នាំ ២០០៩ អស់ **$២៤៥០០ដុល្លា** ។ គិតទាំងផ្សាយតាមវិទ្យុនៅរាជធានីភ្នំពេញនិងតាមបណ្តាខេត្ត ដែលឧបត្ថម្ភកម្មវិធី និងចាក់ផ្សាយតាមទូរទស្សន៍ CTN រួមទាំងចំណាយបច្ច័យ៤ ចង្ហាន់ យានជំនិះព្រះសង្ឃនិមន្តមកសំដែងធម៌។ ថវិកាទាំងអស់នេះបានមកពីសទ្ធាជ្រះថ្លារបស់ពុទ្ធបរិស័ទនិងឯកឧត្តម លោកជំទាវក្នុងនាទីឈ្វេងយល់ព្រះទុទ្ធសាសនា ភាគច្រើនគឺថវិកាផ្ទាល់ខ្លួនរបស់ឧកញ៉ាមហាឧបាសិកា ញឹក ប៊ុនថា។

គ/ ផ្សព្វផ្សាយការងារអប់រំសីលធម៌ តាមខេត្តក្រុងមួយចំនួនជាមួយសិស្សានុសិស្សនៅក្នុងខេត្តក្រុង ដូចជាឆ្នាំ២០០៩ នេះនៅវិទ្យាល័យ ប៊ុន រ៉ានី ហ៊ុន សែន កំពង់ឆ្នាំង មានសិស្ស១៨០០នាក់ចូលរួម ចុះទៅអប់រំនៅសាលាគរុកោសល្យតាខ្មៅចំនួន២លើក មានគរុនិស្សិតចូលរួម៣០០នាក់ នៅសលាគរុកោសល្យភូមិភាគបាត់ដំបង មានគរុនិស្សិតចូលរួម៩៨០នាក់។ ពន្យល់អប់រំផ្ទាល់ដោយ ឧកញ៉ាមហាឧបាសិកា **ញឹក ប៊ុនថា** និងជួយជាថវិកាមួយចំនួន។

ឃ/ រួមសហការជាមួយសមាគមជូនជីនិងឧបាសិកាកម្ពុជរដ្ឋ បង្រៀនធម៌ដល់ដូនជីនិងឧបាសិការួមទាំងសិស្សចូលរួមស្តាប់នៅតាមវត្តជាច្រើនខេត្ត ក្នុងខេត្តចំនួន១៤។ ចូលរួមជាមួយមជ្ឈមណ្ឌលធម្មទានសង្គមកម្ពុជា បំបួសកុលបុត្រនៅវត្ត ភ្សៀត ១៥០នាក់ និងវត្តសានគរ ខេត្តកំពង់ធំ ចំនួន២០០នាក់ ដោយមាន បញ្ចូលការអប់រំសីលធម៌ព្រះពុទ្ធសាសនា។

ង/ ចូលរួមលើឆាកអន្តរជាតិ រួមចំណែកឧបត្ថម្ភគាំទ្រព្រះពុទ្ធសាសនា ដូចជានៅប្រទេសបារាំង នៅព្រះរាជាណាចក្រថៃ ប្រទេសភូមា ប្រទេសស្រីលង្កា និងនៅប្រទេសកូរ៉េខាងត្បូងជាដើម ។

**៣-គណៈកម្មការមនុស្សធម៌ និងសង្គហធម៌**

ក/ ការចុះសួរសុខទុក្ខនិងការជួយឧបត្ថម្ភដល់អ្នកមានទុក្ខ ក្នុងពេលមានសមាជិក ព.ស.ក បានទទួលមរណភាព ឬមានជម្ងឺធ្ងន់ ដើម្បីបានរួមចំណែករំលែកទុក្ខជាមួយគ្រួសារសព ។ ការចុះសួរសុខទុក្ខ អ្នកជម្ងឺនៅ មន្ទីរពេទ្យកុមារជាតិ មន្ទីរពេទ្យសូវៀត មន្ទីរពេទ្យជ័យជំនះ និង មន្ទីរពេទ្យព្រះកុសមៈដែលក្នុងនោះបាន ជួយឧបត្ថម្ភដល់អ្នកផ្ទុកមេរោគអេដស៍ អ្នកមានជម្ងឺទូទៅផងដែរ ។ ប្រារព្ធពិធីបុណ្យព្រហ្មទានប្រគេនតេយ្យធម៌និងថវិកាដល់សមណសិស្ស និស្សិត ដែលរៀន ពូកែចាប់ពីលេខ១ ដល់លេខ៥ ។

**ខ/ ការបណ្តុះបណ្តាលធនធានព្រះសង្ឃ**

-ឆ្នាំសិក្សា ២០០៦-២០០៧ បានជួយអាហារូបករណ៍ដល់សមណនិស្សិត ចំនួន ១០អង្គ។ ឆ្នាំ២០០៨-២០០៩ ចំនួន ១៦អង្គ។ ឆ្នាំ២០០៩-២០១០ ចំនួន៨អង្គ ។ ក្នុងចំនួននេះ លោកជំទាវ ឧកញ៉ា មហាឧបាសិកា ញ៉ឹក ប៊ុនថា ជួយឧបត្ថម្ភ ៨អង្គ គិតជាទឹកប្រាក់ ២.០០០ដុល្លា ។

-ការងារសង្គហធម៌នេះ គឺជាបំណងប្រាថ្នានៃការបង្កើតពុទ្ធិកសមាគមកម្ពុជរដ្ឋ ដែលបានរួមចំណែកជួយរំលែកទុក្ខលំបាករបស់ប្រជាពលរដ្ឋក្រីក្រខ្វះទីពឹង និងជួយដល់អ្នកមានគ្រោះថ្នាក់បន្ទាន់ ដែលទាមទារការលើកទឹកចិត្តព្រមទាំងការសង្គ្រោះទាន់ពេលវេលា ។

- បង្កើតសមាគមមរណៈសង្គ្រោះ បាននឹងកំពុងបំពេញភារកិច្ចយ៉ាងសកម្ម បម្រើការជួយឧបត្ថម្ភជាសម្ភារៈថវិកា ជួយគ្នាពេលមានធុរៈ ឈឺធ្ងន់ និងស្លាប់ ។

**៤-គណៈកម្មការទំនាក់ទំនងសាធារណៈ**

ក/ គណៈកម្មាធិការនាយកពុទ្ធិកសមាគមកម្ពុជរដ្ឋ អាណត្តិបន្តបន្ទាប់បាននឹងកំពុងពង្រឹង និង ពង្រីកសមត្ថភាពស្ថាប័នរបស់ខ្លួន ពង្រីកសមាជិកដោយបានបង្កើតសាខាពុទ្ធិកសមាគមកម្ពុជរដ្ឋ នៅតាមបណ្តាខេត្ត រាជធានីមួយចំនួន ទោះបីបានជួបឧបសគ្គខ្លះៗដល់ដំណើរការពង្រីកសមាជិកភាពក៏ដោយ ។ បានចូលរួមសហការជាមួយ សមាគមអង្គការមិនមែនរដ្ឋាភិបាលដែលមានទិសដៅនិងគោលបំណងប្រហាក់ប្រហែលគ្នាដូចជាសមាគមដូនជីកម្ពុជរដ្ឋ អង្គការសហព័ន្ធសន្តិភាពពិភពលោក និង អង្គការ KEAPដែលមានទីស្នាក់ការនៅកម្ពុជាជាដើម ។

**ខ/ ការចូលរួមការពារបរិស្ថានៈ**

ដោយមើលឃើញអំពីគុណប្រយោជន៍នៃការអប់រំផ្នែកបរិស្ថាន ក្រុមពុទ្ធបរិស័ទ និងយុវពុទ្ធសាសនិកកម្ពុជា ដឹកនាំដោយអ្នកឧកញ៉ាមហាឧបាសិកា **ញ៉ឹក ប៊ុនថា** បានចូលរួមសំអាតបរិស្ថាននៅព្រះសក្យមុនីចេតិយ៍ នាភ្នំព្រះរាជទ្រព្យ ឧត្តុង ដោយបាននាំពុទ្ធបរិស័ទទៅលាងជូតសំអាតព្រះពុទ្ធរូប ក្នុងព្រះសក្យមុនីចេតិយ៍ចំនួន២ដង គឺនៅរៀងរាល់ដើមខែ ចាប់តាំងពីខែមីនា ឆ្នាំ២០០៩នេះ និងក្នុងបរិវេណវត្តឧណ្ណាលោម មានព្រះចេតីយរបស់**សម្តេច ជួន ណាត** ព្រះវិហារវត្តឧណ្ណាលោម បរិវេណវត្ត និង ព្រះវិហារវត្តបុទុមវតី និង វត្តវិហារសំណជាដើម ។ ចូលរួមដាំដើមឈើនៅសាលាគរុកោសល្យភូមិភាគ ខេត្ត

បាត់ដំបង និងវត្តត្រាំនាគ ខេត្តសៀមរាប។ សកម្មភាពនេះគឺមានបំណង បង្ហាញដល់សាធារណជនឱ្យបានដឹងថាការងារសំអាតបរិស្ថានគឺជាការងាររួមចំណែកថែរក្សាសុខភាពនិងថែរក្សានូវសម្បត្តិ វប្បធម៌សាធារណៈ ការពារបរិស្ថានស្អាតល្អ មានអនាម័យសម្រាប់ជីវិតរស់នៅ និងធ្វើឱ្យមានសោភ័ណភាពសម្រាប់កន្លែងធ្វើពុទ្ធបូជា ហើយក៏ជាទង្វើដ៏ប្រពៃសម្រាប់មនុស្សជំនាន់ក្រោយ និងអាចចាត់ទុកជាសកម្មភាពគំរូសម្រាប់កន្លែងនានា ក្នុងពុទ្ធមណ្ឌលផ្សេងៗ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**៥- គណៈកម្មការគ្រប់គ្រងហិរញ្ញវត្ថុ**

ពុទ្ធិកសមាគមកម្ពុជរដ្ឋ មានប័ណ្ណចំណូលចំណាយតាមសំណើ និងឯកសារពិតប្រាកដ។ មានស្នងការ គណនេយ្យជាអ្នកត្រួតពិនិត្យគណកម្មាធិការនាយកដែលសម្រេចចំណាយត្រឹមត្រូវឬមិនត្រឹមត្រូវ។

គណៈកម្មាការគ្រប់គ្រងហិរញ្ញវត្ថុបានខិតខំរៀបចំគ្រប់គ្រងការងាររបស់ខ្លួន ដោយមានការរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងបានត្រឹមត្រូវ ប្រកបដោយ គណនេយ្យភាព និងតម្លាភាព។

ថវិកា ព.ស.ក ក្នុងឆ្នាំ ២០០៩ គិតពីខែ មករា រហូតដល់ខែ វិច្ឆិកា ២០០៩

-សំណល់ ចុងឆ្នាំ ២០០៨ មាន ៣ ៦៦៨ ៥៤៥៛

-ប្រាក់ចំណូល ១២ ៧៧៧ ០០០៛

-ប្រាក់ចំណាយ ១៥ ៦៣៤ ១០១៛

-សំណល់ក្នុងបេឡា ៨១១ ៤៤៣៛

ថវិកា ព.ស.ក តម្កល់ទុកនៅធនាគារ គិតត្រឹមខែវិច្ឆិកា ២០០៩ មានចំនួន

-ប្រាក់រៀល ២៨ ៦០៧ ៤១៦៛

-ប្រាក់ដុល្លា $៨៥៩.៧៥ ដុល្លា

✵ -ប្រាក់ឧបត្ថម្ភដោយសប្បុរសជន ក្នុងកិច្ចការរដ្ឋបាលរបស់ពុទ្ធិកសមាគមកម្ពុជរដ្ឋ ចាប់ពីឆ្នាំ ២០០៨ ដល់ខែ ១១ ឆ្នាំ ២០០៩ សរុបទឹកប្រាក់ ២០ ៨៦៧ ៥០០៛ និង ប្រាក់ដុល្លា $ ១១០០ ដុល្លា ។ ក្នុងនោះទទួលបានពី

-ឧកញ៉ាមហាឧបាសិកា ញ៉ឹក ប៊ុនថា ១៨ ៤៥៧ ៥០០ ៛ និង $៦០០ ដុល្លា

-ឯកឧត្តម ឡុច សារិន ៤០០ ០០០៛ និងប្រាក់ដុល្លា $១០០ ដុល្លា

-ភិក្ខុ យឿង យ៉ាត់ $២០០ដុល្លា

-ឯកឧត្តម សារ៉ាយ ឆុន $១០០ ដុល្លា

-លោក ឈិម កន $១០០ ដុល្លា

✵ ប្រាក់ឧបត្ថម្ភបោះពុម្ពលក្ខន្តិកៈ

-ឧកញ៉ាមហាឧបាសិកា ញ៉ឹក ប៊ុនថា $៣០០ដុល្លា និង

-លោកជំទាវ សុខ កែវ ចាន់សារុន ១ ០០០ ០០០៛ រៀល

-លោក មាស ខេង និងលោកស្រី មូរ វួច ១ ០០០ ០០០៛ រៀល

-លោកស្រី តាន់ ស៊ីវឡាង និង ស្វាមី $២០០ ដុល្លា និងលោកស្រី ទឹម សាមី $១០០ ដុល្លា

-លោក ចាន់ ធឿន និងលោកស្រី សេង សុខុម $១០០ ដុល្លា និងលោកជំទាវ ហាក់ ជូ $១០០ ដុល្លា

-លោកស្រី កាំង ប៉ូលីន $១០០ ដុល្លា និងលោក ជា សុខុម លោកស្រី អ៊ុន ពុន $១០០ ដុល្លា

-កញ្ញា ខេង ច័ន្ទគ្រីស្នា $៥០ ដុល្លា

**ព្រះនាមរបស់រាជាគណ និង មន្ត្រីសង្ឃគ្រប់ជាន់ថ្នាក់ ចូលរួមវិភាគទានសម្រាប់ទ្រទ្រង់ការងារពុទ្ធិកសមាគម កម្ពុជរដ្ឋឆ្នាំ ២០១០ គិតចាប់ពីខែមករា ដល់ខែមិថុនា ២០១០ ក្នុងឱកាសធ្វើសិក្ខាសាលា ព.ស.ក ២៦-១២-០៩**

| | | | |
|---|---|---|---|
| ១- | សម្តេចព្រះមហាសុមេធាធិបតី នន្ទ ង៉ែត | បង់ ៦ខែ | ៦០០.០០០៛០០ |
| ២- | សម្តេចព្រះវន័រត្ន ណយ ច្រឹក | បង់ ៦ខែ | ៦០០.០០០៛០០ |
| ៣- | សម្តេចព្រះពោធិវង្ស អំ លឹមហេង | បង់ ៦ខែ | ៦០០.០០០៛០០ |
| ៤- | សម្តេចព្រះអរិយវង្ស សោវ៍ ច័ន្ទថុល | បង់ ៦ខែ | ៣០០.០០០៛០០ |
| ៥- | ព្រះពុទ្ធវង្ស ជា សំអាង | បង់ ៦ខែ | ៣០០.០០០៛០០ |
| ៦- | ព្រះមេធ សុវង្ស អឿ សំអាន<br>វត្តជំពូវ័ន្ត អនុគណ ខ័ណ្ឌ ដង្កោ រាជធានីភ្នំពេញ | បង់ ១ឆ្នាំ | ៦០០.០០០៛០០ |
| ៧- | ព្រះមុនីវង្ស សៀង សុខ មេគណ | បង់ ៦ខែ | ៣០០.០០០៛០០ |
| ៨- | ព្រះចៅអធិការ វត្តមហាមន្ត្រី ខៀវ អឿន | បង់ ១ឆ្នាំ | ១២០.០០០៛០០ |
| ៩- | ព្រះវិសុទ្ធិវង្ស អ៊ុក មុត ព្រះមេគណ ខេត្តបាត់ដំបង | បង់ ៦ខែ | ១០០.០០០៛០០ |
| ១០- | ព្រះគ្រូសិរីសត្ថា ហេង សុខន ព្រះអនុគណ<br>ស្រុកថ្មគោល ខេត្តបាត់ដំបង | បង់ ៦ខែ | ៥០.០០០៛០០ |

**នាមសប្បុរសជនដែលបានជួយទ្រទ្រង់ការងារពុទ្ធិកសមាគមកម្ពុជរដ្ឋ ឆ្នាំ ២០១០**

| | | | |
|---|---|---|---|
| ១- | លោក មាស ខេង និងលោកស្រី មួរ វួច | បង់ ១ឆ្នាំ | ២០០០.០០០៛០០ |
| ២- | កញ្ញា ខេង ច័ន្ទគ្រីស្នា | បង់ ១ឆ្នាំ | $១២០ ដុល្លា |
| ៣- | ឧបាសិកា វេជ្ជបណ្ឌិត តុល ចន្ទបូនី | បង់ ៦ខែ | ៥០$០០ |
| ៤- | ឧបាសិកា អ៊ូ សុខសាន ព្រមទាំងបុត្រ | បង់ ៦ខែ | ៣០$០០ |

ថវិកាដែលបានកត់ត្រាទុកខាងលើនេះ គឺជាសក្ខីភាពមួយដែលបង្ហាញថា ទាំងគ្រហស្ថ និងបព្វជិត មានសទ្ធាជ្រះថ្លា និងបូជារាល់កម្លាំងកាយចិត្តដើម្បីការងារព្រះពុទ្ធសាសនា ដោយឥតងាករេ។ សក្ខីកម្មទាំងឡាយនេះ យើងខ្ញុំសូមលើកឧទ្ទិសជូនបុព្វការីជនរបស់លោកសប្បុរសទាំងអស់សូមលោកទទួលបាននូវសេចក្តីសុខ និង ចម្រើន ព្រមទាំងបានសម្រេចនូវបំណងប្រាថ្នាកុំបីឃ្លៀងឃ្លាតឡើយ។

- ***សមាជិកភាព:***

បើគិតមកទល់សព្វថ្ងៃនេះ សមាជិកដែលចូលរួមជ្រោមជ្រែងពុទ្ធិកសមាគមកម្ពុជរដ្ឋឱ្យមានដំណើរការល្អតាមលក្ខន្តិកៈ នៅមានចំនួនតិចតួចនៅឡើយ បើប្រៀបធៀបចំនួនអ្នកកាន់ព្រះពុទ្ធសាសនា ព្រោះគេមិនទាន់ជ្រួតជ្រាបពីសារៈប្រយោជន៍ ក្នុងការ

ចូលរួមជាកម្លាំងជាមួយ ព.ស.ក. ដើម្បីគោរពប្រតិបត្តិទ្រទ្រង់លើកដំកើងព្រះពុទ្ធសាសនា និងកសាងសង្គមជាតិ។

## IV/ ទិសដៅការងារបន្ត

១-ជម្រុញគណៈកម្មការបណ្ដោះអាសន្ន ព.ស.ក ខេត្ត-ក្រុងទាំងអស់ ធ្វើមហាសន្និបាតជ្រើសតាំងគណៈកម្មការពេញសិទ្ធិ និងជម្រុញឱ្យមានគណៈកម្មការបណ្ដោះអាសន្ន ព.ស.ក ខេត្ត-ក្រុង ដែលមិនទាន់មានឱ្យមានឡើង។

២-ប្រើប្រាស់គ្រប់រូបភាពដើម្បីពង្រីងពង្រីកសមាជិក ព.ស.ក នៅតាមក្រសួងមន្ទីរ ស្ថាប័ន អង្គភាពរាជធានី ខេត្តក្រុង និងតាមវត្តអារាម ជ្រើសរើសព្រះសង្ឃ ពុទ្ធិបរិស័ទ នៅតាមវិទ្យាល័យ សលាបឋមសិក្សា និង តាមមណ្ឌលសហគមន៍ តាមសាលារៀនទាំងឯកជន និងរដ្ឋ និងតាមបណ្ដាស្ថាប័ននានា។

៣-បន្តបោះពុម្ពទស្សនាវដ្ដី "**ពន្លឺពុទ្ធចក្រ** " តាមគម្រោងកំណត់ និងស្រាវជ្រាវបោះពុម្ពសៀវភៅ ធម៌វិន័យ ទំនៀមទម្លាប់ខ្មែរ មានអត្ថន័យខ្លឹមសារ គួរដល់ការផ្សព្វផ្សាយទាំងក្នុង និងក្រៅប្រទេសជាពិសេស ប្រវត្តិនៃពិធីបុណ្យព្រះពុទ្ធសាសនា ពុទ្ធភាសិតខ្លីៗ រឿងបុគ្គលាធិដ្ឋាន រឿងជាតក ។ល។

៤-ពង្រីកការងារអប់រំសីលធម៌និងវប្បធម៌សន្តិភាពតាមរយៈ នាទីឈ្វេងយល់ព្រះពុទ្ធសាសនា នាទីសន្ទនាធម៌តាមវិទ្យុ និងតាមទូរទស្សន៍ឱ្យកាន់តែមានកម្រិតទូលាយជាងមុន និងរកប្រធានបទពាក់ព័ន្ធ ទៅនឹងបច្ចុប្បន្នភាពរបស់សង្គមមានបញ្ហាអប់រំយុវវ័យ កាត់បន្ថយអំពើហិង្សា គោរពច្បាប់ និងទប់ស្កាត់អំពើជួញដូរមនុស្ស និងគ្រឿងញៀនជាដើម។

៥-បន្តសកម្មភាពប្រជាសង្គ្រោះ និងបន្តជួយឧបត្ថម្ភជាអាហារូបករណ៍ដល់សមណសិស្ស រួមទាំងធ្វើពិធីបុណ្យព្រហ្មទានដល់សមណសិស្ស សមណនិស្សិតដែល រៀនពូកែ ត្រូវបន្តការសិក្សា តាមគោលការណ៍កំណត់។

៦-ទំនាក់ទំនងទូលាយជាមួយស្ថាប័ននានា ដូចជាក្រសួងធម្មការនិងសាសនា ក្រសួងអប់រំយុវជន និងកីឡា ក្រសួងសង្គមកិច្ច ក្រសួងកិច្ចការនារីជាដើម រួមទាំងអង្គការសង្គមស៊ីវិល អង្គការមនុស្សធម៌ អង្គការសមាគម ក្នុងនិងក្រៅប្រទេស អំពាវនាវរកការជួយឧបត្ថម្ភសម្ភារៈ ថវិកា និងស្មារតី បម្រើឱ្យការប្រព្រឹត្តទៅរបស់ ព.ស.ក .។

សេចក្ដីរាយការណ៍ដូចបានគោរពជម្រាបជូនដូចខាងលើ គឺជាសេចក្ដីសង្ខេបអំពីសកម្មភាពពុទ្ធិកសមាគមកម្ពុជរដ្ឋដើម្បីថ្វាយនិងប្រគេន ចំពោះសម្ដេចព្រះសង្ឃរាជទាំងពីរគណៈ ព្រះសង្ឃនាយកនិងព្រះសង្ឃនាយករង និងមន្ត្រីសង្ឃគ្រប់ថានុក្រមទាំងអស់ ព្រមទាំងជម្រាបជូនគណៈអធិបតី និងសមជិកសមាជិកា អង្គសិក្ខាសាលាទាំងអស់បានជ្រាបជាព័ត៌មាន។

អាស្រ័យហេតុដូចនេះ ទូលព្រះបង្គំ ខ្ញុំព្រះករុណា/នាងខ្ញុំ សូមសម្ដេច ព្រះមន្ត្រីសង្ឃ គណៈអធិបតីអង្គពិធីសមាជិកសមាជិកាពុទ្ធិកសមាគមកម្ពុជរដ្ឋទាំងអស់ មេត្តាផ្ដល់ការណែនាំ បទពិសោធន៍ វិធីសាស្ត្រ និងអនុសាសន៍ដ៏ខ្ពង់ខ្ពស់ដើម្បីតម្រង់ទិសការងារ ក៏ដូចជាការពង្រីកសមាជិកគាំទ្រឱ្យបានច្រើន ដល់គណៈកម្មាធិការនាយកពុទ្ធិកសមាគមកម្ពុជរដ្ឋ បន្តអនុវត្តនិងធ្វើសកម្មភាពនាពេលអនាគតប្រកបដោយជោគជ័យ ក្នុងការរួមចំណែកផ្សព្វផ្សាយលើកដំកើងព្រះពុទ្ធសាសនាឱ្យជ្រួតជ្រាបគ្រប់ស្រទាប់គ្រប់វ័យ ដើម្បីអភិវឌ្ឍន៍ព្រះពុទ្ធសាសនានិងសង្គមជាតិឱ្យរីកចម្រើនតទៅ ដោយសេចក្ដីអនុគ្រោះបំផុត។

ធ្វើនៅរាជធានីភ្នំពេញ. ថ្ងៃទី ២៦ ខែធ្នូ ឆ្នាំ ២០០៩

**គណៈកម្មាធិការនាយកពុទ្ធិកសមាគមកម្ពុជរដ្ឋ**